**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**រដ្ឋបាលជលផល**

លេខ:.....៤៦៤០.....ជផ

# សេចក្តីជូនដំណឹង
## ស្តីពី
## ការបិទនេសាទរូសត្រីក្រឡាហ្វូល ឆ្នាំ២០១៨
## ក្នុងដែននេសាទសមុទ្រកម្ពុជា

**យោង** : - ព្រះរាជក្រមលេខនស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល

- ប្រកាសលេខ០៥២ ប្រក.កសក ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០២ ស្តីពីការកំណត់ឧបករណ៍នេសាទឈ្នាងរូសត្រីក្រឡាហ្វូលឱ្យធ្វើអាជីវកម្មនេសាទ
- ប្រកាសលេខ១៨៣ ប្រក.កសក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០២ ស្តីពីការកែសម្រួលប្រកាសលេខ០៥២ ប្រក.កសក ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០២ ស្តីពីការកំណត់ឧបករណ៍នេសាទឈ្នាងរូសត្រីក្រឡាហ្វូលឱ្យធ្វើអាជីវកម្មនេសាទ។

រដ្ឋបាលជលផល សូមជូនដំណឹងដល់សាធារណជនប្រកបរបរនេសាទសមុទ្រទាំងអស់ឱ្យបានជ្រាបថា ការធ្វើអាជីវកម្មនេសាទត្រីក្រឡាហ្វូលនៅក្នុងដែននេសាទសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា ត្រូវផ្អាកសកម្មភាពនេសាទចាប់ពីថ្ងៃទី០១ ខែកញ្ញា រហូតដល់ថ្ងៃទី៣១ ខែតុលា ជារៀងរាល់ឆ្នាំ។ នៅក្នុងរយៈពេលបិទនេសាទនេះ គឺជារដូវពងកូនបន្តពូជរបស់ត្រីក្រឡាហ្វូល។

រដ្ឋបាលជលផលសង្ឃឹមថា សាធារណជននិងអ្នកនេសាទទាំងអស់ នឹងអនុវត្តតាមសេចក្តីជូនដំណឹងនេះ ដើម្បីចូលរួមចំណែកថែរក្សានិងការពារធនធានជលផលសមុទ្រឱ្យបានគង់វង្សទៅថ្ងៃអនាគត។

អាស្រ័យហេតុនេះ សូមអ្នកនេសាទទាំងអស់ជ្រាបនិងផ្អាកការនេសាទត្រីក្រឡាហ្វូលតាមកាលកំណត់ខាងលើ ហើយអ្នកនេសាទទាំងអស់និងបន្តធ្វើនេសាទនៅពេលផុតកំណត់រយៈពេលបិទនេសាទនេះ។ ៥ស/ក

ថ្ងៃអង្គារ ៧ រោច ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែសីហា ឆ្នាំ២០១៨

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**

**ប្រធានរដ្ឋបាលជលផល**

**អេង ជាសាន**

**ចម្លងជូន:**
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
  - ដើម្បីជូនជ្រាបជាព័ត៌មាន -
- រដ្ឋបាលខេត្តពាក់ព័ន្ធ
  - ដើម្បីជួយជំរុញការអនុវត្តឱ្យមានប្រសិទ្ធភាព -
- មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទពាក់ព័ន្ធ
- អធិការដ្ឋានរដ្ឋបាលជលផលសមុទ្រ
- ខណ្ឌរដ្ឋបាលជលផលពាក់ព័ន្ធ
  - ដើម្បីរួមសហការ -
- ឯកសារ កាលប្បវត្តិ

អាសយដ្ឋាន:អាគារលេខ១៨៦ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ប្រអប់សំបុត្រលេខ៥៨២ ☏/Fax:(855) 23 215 470 www.fia.gov.kh
Address #186 Preah Norodom Blvd., Sangkat Tonle Bassac, Khan Chamcar Mon, Phnom Penh capital, Cambodia. P.O Box 582. ☏/Fax: (855) 23 215 470 www.fia.gov.kh